# សូត្រខ្មែរ



សរសៃសូត្រដែលត្បាញចេញពីសំបុកដង្កូវនាង

***សូត្រ*** ( ន. ) ចេស; ខ្សែធ្មារ; សរសៃធ្មារល្អិត (មានសរសៃពីងពាង, សរសៃឈូកជាដើម) ។ សរសៃដែលស្រាវយកពីសំបុកដង្កូវនាង : ស្រាវសូត្រ, សំពត់សូត្រ ។



ហូលគោមចិញ្ចៀនពេជ្រ

***ហូល*** (សំលៀកបំពាក់) ( ន. ) ឈ្មោះសំពត់សូត្ររបស់ខ្មែរ ត្បាញដោយសូត្រចងគាធលើកជាគោមជាក្រឡាក្បាច់រចនាវិចិត្រផ្សេងៗតាមចំពោះនិងសេចក្តីពេញចិត្តនៃអ្នកត្បាញ។ សំពត់ហូលសម្រាប់ស្ត្រីមានគោមតូចៗដូចជា រូបផ្កាម្ទេស ផ្កាទទឹម សត្វពីងពាង សត្វអណ្តើកជាដើម។ សម្រាប់បុរសស្លៀក គេលើកគោមធំៗមាន រូបសត្វដំរី សត្វនាគ សត្វហង្ស សត្វគ្រុឌ។ ហូលជរ ហូលដែលត្បាញលើកជាក្បាច់ជរត្រង់ជាយ ។



ផាមួង

***ផាមួង*** ស. ( ន. ) ឈ្មោះសំពត់សូត្រមួយប្រភេទមានពណ៌លាតផ្សេងៗសម្រាប់ស្លៀក, កំណើតធ្វើក្នុងកម្ពុជរដ្ឋ : ផាមួងព័ណ៌ព្រីងទុំ, ផាមួងព័ណ៌ស្វាទុំ ។ ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាត និង ពណ៌ផ្សេងៗ ជួនមានបន្តក់ជរជើងនិងមានបន្តក់លើផ្ទៃសំពត់។ សំពត់ដែលមានបន្តក់ឬជរជើងត្បាញពីអំបោះសម្រាប់ស្លៀកពេលថ្ងៃ។ ចំណែកសំពត់ដែលមានបន្តក់ឬជរជើងត្បាញពីខ្សែពណ៌ទឹកមាស ឬទឹកប្រាក់មានពន្លឺចែងចាំង សម្រាប់ស្លៀកនៅពេលយប់។

***( សំពត់ )សឹង*** ជាក្រណាត់សំពត់ដែលត្បាញឡើងពីអំបោះ មានជាពងលាត និងក្បាច់រចនាដូចហូល និងផាមួងដែរ តែខុសត្រង់ថាហូល និងផាមួងត្បាញឡើងពីសរសៃសូត្រ ដែលផលិតចេញពីសត្វដង្កូវនាង ឯសំពត់សឹង គឺត្បាញចេញពីសរសៃអំបោះ ដែលផលិតចេញពីសំលីកំបាស់។

រូបភាព១-សំពត់សឹងខ្មែរ



រូបភាព២-សំពត់សឹងថៃ



រូបភាព៣-សំពត់សឹងឡាវ

